សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណង**

ច្បាប់នេះ កំណត់អំពីបែបបទ នីតិវិធី និងលក្ខខណ្ឌនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ននៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រមទាំងការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ននេះ ដើម្បីការពារសន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិតនិងសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងការពារទ្រព្យសម្បត្តិនិងបរិស្ថាន។

**មាត្រា ២.- វិសាលភាព**

ច្បាប់នេះ មានវិសាលភាពអនុវត្តនៅពេលដែលប្រទេសជាតិត្រូវបានដាក់ស្ថិតក្នុងស្ថានភាពអាសន្ន ស្របតាមមាត្រា ២២ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## បែបបទ នីតិវិធី និងលក្ខខណ្ឌ
## នៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

**មាត្រា ៣.- បែបបទ និងនីតិវិធីនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន**

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។

ការប្រកាសដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន អាចធ្វើឡើងសម្រាប់ថិរវេលាមានកំណត់ ឬសម្រាប់ថិរវេលាមិនកំណត់។ ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នសម្រាប់ថិរវេលាមិនកំណត់ ត្រូវបញ្ចប់ដោយព្រះរាជក្រឹត្យនៅពេលសភាពការណ៍អនុញ្ញាត។

**មាត្រា ៤.- លក្ខខណ្ឌនៃការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន**

ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន អាចធ្វើឡើងនៅពេលដែលប្រជាជាតិប្រឈមមុខនឹង

គ្រោះថ្នាក់ ជាអាទិ៍ គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាម ឬការឈ្លានពានពីកម្លាំងបរទេស គ្រោះអាសន្ន បន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងគ្រោះមហន្តរាយធ្ងន់ធ្ងរ ដែលគម្រាមកំហែង ឬអាចបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេស។

## ជំពូកទី ៣
## ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

### មាត្រា ៥.- វិធានការក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

នៅពេលប្រទេសជាតិត្រូវបានប្រកាសដាក់ស្ថិតនៅក្នុងភាពអាសន្ន រាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញវិធានការដូចខាងក្រោម៖

១.ការហាមឃាត់ ឬការកម្រិតសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ។

២.ការហាមឃាត់ ឬការកម្រិតសិទ្ធិសេរីភាពក្នុងការជួបជុំ ឬការប្រមូលផ្តុំមនុស្ស។

៣.ការហាមឃាត់ ឬការកម្រិតការធ្វើសកម្មភាពការងារ ឬមុខរបរ។

៤.ការហាមឃាត់ ឬការកម្រិតមិនឱ្យបុគ្គលចេញពីលំនៅឋាន ឬទីសំណាក់ណាមួយ។

៥.ការដាក់ចេញវិធានការចត្តាឡីស័ក ឬការដាក់ឱ្យនៅដោយឡែកក្នុងករណីគ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺ។

៦.ការដាក់ចេញវិធានការទាក់ទងនឹងកំណែន និងជម្លៀសពលរដ្ឋ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

៧.ការដាក់ចេញវិធានការទាក់ទងនឹងកំណែន ដកហូត គ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ និងសេវា ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។ នីតិវិធីនៃការធ្វើកំណែន និងសំណងត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

៨.ការដាក់ចេញវិធានការទាក់ទងនឹងការកំណត់ថ្លៃទំនិញ និងសេវា ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

៩.ការដាក់ចេញវិធានការទាក់ទងនឹងការបិទទីតាំងសាធារណៈ ឬឯកជនណាមួយ ដែលមានភាពចំាបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

១០.ការដាក់ចេញនូវវិធានការឃ្លាំមើល និងតាមដានតាមគ្រប់មធ្យោបាយ ដើម្បីទទួល

បានព័ត៌មានតាមរយៈប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍គ្រប់ប្រភេទ ក្នុងគោលបំណងឆ្លើយតបចំពោះភាពអាសន្ន។

១១.ការហាមឃាត់ ឬការកម្រិតការចែកចាយ ឬការផ្សព្វផ្សាយព័ត៌មានដែលអាចបង្កឱ្យមានការភ័យខ្លាចដល់សាធារណជន ឬចលាចល ឬដែលនាំឱ្យខូចខាតដល់សន្តិសុខជាតិ ឬធ្វើឱ្យមានការភាន់ច្រឡំអំពីស្ថានភាពនៃភាពអាសន្ន។

១២.ការដាក់ចេញវិធានការផ្សេងទៀតដែលសមស្រប និងចាំបាច់ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

វិធានការអនុវត្តពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន អាចត្រូវបានដាក់ចេញសម្រាប់ទូទាំងប្រទេស ឬដែនដីកំណត់ជាក់លាក់ណាមួយ។

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចបង្កើតយន្តការ ឬប្រគល់សិទ្ធិអំណាចទៅអាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ដើម្បីធានាដល់ការអនុវត្តវិធានការខាងលើ។

ក្នុងពេលសង្គ្រាម ឬក្នុងកាលៈទេសៈផ្សេងទៀតដែលសន្តិសុខជាតិប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នបែបនេះ អាចធ្វើឡើងតាមរបបអាជ្ញាសឹក។

**មាត្រា ៦.- របាយការណ៍អំពីវិធានការក្នុងភាពអាសន្នជូនរដ្ឋសភា និងព្រឹទ្ធសភា**

រាជរដ្ឋាភិបាលត្រូវរាយការណ៍ជាប្រចាំអំពីវិធានការដែលខ្លួនបានដាក់ចេញក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ជូនទៅរដ្ឋសភា និងព្រឹទ្ធសភា។ រដ្ឋសភា និងព្រឹទ្ធសភា អាចស្នើសុំព័ត៌មានចាំបាច់បន្ថែមផ្សេងទៀតពីរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យ និងការវាយតម្លៃអំពីវិធានការដែលបានដាក់ចេញក្នុងពេលដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**ជំពូកទី ៤**

**ទោសប្បញ្ញត្តិ**

**មាត្រា ៧.- បទរាំងដល់កិច្ចប្រតិបត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន**

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌផ្សេងទៀត អំពើដោយចេតនារាំង ឬបង្កឧបសគ្គដល់កិច្ចប្រតិបត្តិការឆ្លើយតបចំពោះភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ)

ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

អំពើរាំងដល់កិច្ចប្រតិបត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះ នាំឱ្យមានចលាចលជាសាធារណៈ ឬប៉ះពាល់ដល់សន្តិសុខជាតិ។

## មាត្រា ៨.- បទមិនគោរពវិធានការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនាមិនគោរពវិធានការដាក់ចេញដោយរាជរដ្ឋាភិបាលក្រោមបញ្ញត្តិនៃមាត្រា ៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

អំពើមិនគោរពតាមវិធានការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល កាលបើអំពើនេះ នាំឱ្យមានចលាចលជាសាធារណៈ។

## មាត្រា ៩.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ទៅ ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១០.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.- ការប្រកាសជាការប្រញាប់**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ..............ខែ...........ឆ្នាំ........ស័ក ព.ស.........
ត្រូវនឹងថ្ងៃទី.........ខែ..........ឆ្នាំ..........នាសម័យប្រជុំរដ្ឋសភា
លើកទី..............នីតិកាលទី...........។
រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ...........ឆ្នាំ............
**ប្រធានរដ្ឋសភា**